# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

ថ្ងៃអង្គារ ៦កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៧

### សារជូនពរ
### ផ្ញើជូន
### នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ
### នៅក្នុងឱកាសទិវាចូលឆ្នាំថ្មីឆ្នាំសកល២០១៨

**ឯកឧត្តម លោកជំទាវ មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទទាំងអស់ ជាទីស្នេហា !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មីឆ្នាំសកល ២០១៨ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ កងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសាកសួរសុខទុក្ខ ដោយក្តីនឹករលឹកនិងជាទីស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុត សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនដល់ ឯកឧត្តម លោកជំទាវ ជានាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាពនានា ក៏ដូចជាសិក្ខាកាមកំពុងសិក្សាជំនាញផ្សេងៗនៅបណ្តាប្រទេសមួយចំនួនជាមិត្ត ព្រមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ សូមទទួលបានជោគជ័យថ្មីៗបន្តទៀតជូនជាតិមាតុភូមិ។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះ ចំពោះជោគជ័យដ៏ត្រចះត្រចង់នូវសមិទ្ធផលដ៏ធំធេងក្នុងឆ្នាំកន្លងមក ក្នុងកិច្ចការពារជាតិមាតុភូមិ ជាពិសេសនៅក្នុងសភាពការណ៍ចុងក្រោយនេះ កងយោធពលខេមរភូមិន្ទយើងស្ថិតនៅជាកម្លាំងស្នូលក្នុងការថែរក្សា ការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ ទប់ស្កាត់ឧបាយកលនាំមក " **បដិវត្តន៍ពណ៌** " នៅកម្ពុជាដោយប្រកាន់ជំហរប្រឆាំងដាច់ខាត ចំពោះជនក្បត់ជាតិ និងក្រុមឱកាសនិយមទាំងឡាយណា ដែលនាំប្រទេសជាតិឲ្យធ្លាក់ក្នុងមហន្តរាយបំផ្លាញសន្តិភាព ធ្វើឲ្យប៉ះពាល់ដល់ភាពសុខក្សេមក្សាន្តរបស់ប្រជាជន។ ទន្ទឹមនឹងនេះ ជានិច្ចកាលកងយោធពលខេមរភូមិន្ទប្តេជ្ញាដាច់ខាត ការពាររដ្ឋធម្មនុញ្ញ ការពាររាជបល្ល័ង្ក ការពាររាជរដ្ឋាភិបាលស្របច្បាប់ កើតចេញពីការបោះឆ្នោតតាមឆន្ទៈរបស់ប្រជាពលរដ្ឋ និងរួមចំណែករក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម ដើម្បីសន្តិភាពនិងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ។

ជាមួយនេះដែរ កងយោធពលខេមរភូមិន្ទបានបំពេញតួនាទីភារកិច្ចយ៉ាងសកម្មក្នុងការកែទម្រង់ លើកកម្ពស់សមត្ថភាពធនធានមនុស្សក្នុងជួរកងទ័ព ពង្រឹងការឈរជើងការពារបានរឹងមាំ នៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសជិតខាង ព្រមទាំងចូលរួមជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះ ដោយគ្រោះមហន្តរាយនានា ដែលកើតមានឡើងជាយថាហេតុ។

ក្រៅពីនេះទៀត កងយោធពលខេមរភូមិន្ទ ក៏បានចូលរួមអនុវត្តប្រកបដោយជោគជ័យនូវភារកិច្ចអន្តរជាតិលើវិស័យមនុស្សធម៌ បំពេញបេសកកម្មជាកងកម្លាំងរក្សាសន្តិភាព ក្រោមឆត្ររបស់អង្គការសហប្រជាជាតិ នៅបណ្តាតំបន់មួយចំនួនដូចជា " **អាហ្វ្រិក អឺរ៉ុប និងមជ្ឈិមបូព៌ា** " ដើម្បីបុព្វហេតុសន្តិភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ដែលជាក្តីមោទនភាព និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់របស់កងយោធពលខេមរភូមិន្ទ ក៏ដូចជាប្រជាជាតិកម្ពុជាយើងទាំងមូល មិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពីមុនមក។